## គម្រោងចាក់ថ្នាំបង្ការរោគ រដ្ឋញូវសៅវែល

បើកមើលវ៉ិបសៃថ៍របស់ក្រសួងសុខាភិបាល រដ្ឋញូវសៅវែល ដើម្បីពិនិត្យ គម្រោងចាក់ថ្នាំបង្ការរោគ រដ្ឋញូវសៅវែល បច្ចុប្បន្ននៅត្រង់៖ www.health.nsw.gov.au/schedule

## Save the Date to Vaccinate (កត់ទុកកាលបរិច្ឆេទដើម្បីចាក់ថ្នាំបង្ការរោគ)

ការចាក់ថ្នាំបង្ការរោគទាន់ពេលវេលា គឺជាការការពារដ៏ល្អបំផុតរបស់កូនអ្នក ដើម្បីប្រឆាំងជំងឺធ្ងន់ធ្ងរទាំងឡាយ។ កម្មវិធី ‘Save The Date To Vaccinate’ អាចជួយអ្នកឱ្យប្រាកដថា ការចាក់ថ្នាំបង្ការរោគរបស់កូនអ្នកត្រូវបានផ្តល់ជូនទាន់ពេលវេលា។




ចូលទៅកាន់វ៉ិបសៃថ៍ ‘Save The Date To Vaccinate’ ដើម្បីទាញយកកម្មវិធី និងបង្កើតគម្រោងចាក់ថ្នាំបង្ការរោគដែលបានណែនាំ របស់គ្រួសារអ្នក៖ www.health.nsw.gov.au/immunisation




## កំណត់ត្រាសុខភាពផ្ទាល់ខ្លួនរបស់ខ្ញុំ (សៀវភៅពណ៌ខៀវ)

ជាការសំខាន់ដែលត្រូវយកសៀវភៅពណ៌ខៀវរបស់កូនអ្នក ទៅកាន់ការណាត់ជួបនីមួយៗ ដើម្បីឱ្យវេជ្ជបណ្ឌិត / គិលានុបដ្ឋាកកត់ត្រាការចាក់ថ្នាំបង្ការរោគ របស់កូនអ្នក។

## ទម្រង់បែបបទ កំណត់ត្រាការចាក់ថែងថ្នាំបង្ការរោគសម្រាប់មនុស្សពេញវ័យ

ទម្រង់បែបបទ *កំណត់ត្រាការចាក់ថែងថ្នាំបង្ការរោគសម្រាប់មនុស្សពេញវ័យ* អាចទទួលយកបាននៅតាមវ៉ិបសៃថ៍ www.health.nsw.gov.au/recordvaccines ដែលអាចជួយអ្នកក្នុងការតាមដានការចាក់ថ្នាំបង្ការរោគរបស់អ្នក។

## ព័ត៌មានបន្ថែម

### ក្រសួងសុខាភិបាល រដ្ឋញូវសៅវែល

www.health.nsw.gov.au/immunisation

### បញ្ជីចាក់ថ្នាំបង្ការរោគអូស្ត្រាលី

https://www.humanservices.gov.au/individuals/services/medicare/australian-immunisation-register

### ក្រសួងសុខាភិបាល រដ្ឋាភិបាលអូស្ត្រាលី

https://beta.health.gov.au/health-topics/immunisation

### កម្មវិធីចាក់ថ្នាំបង្ការរោគក្អកមាន់មុនពេលសម្រាលកូន រដ្ឋញូវសៅវែល

www.health.nsw.gov.au/protectnewborns

SHPN (HP NSW) 190523
July 2019 © NSW Ministry of Health

Khmer

# ការមានផ្ទៃពោះ

## ការការពារ និងការចាក់ថ្នាំបង្ការរោគចាប់ពីមុនពេលមានផ្ទៃពោះទៅពេលសម្រាលកូន



NSW GOVERNMENT

## មុនពេលអ្នកមានផ្ទៃពោះ

មុនពេលមានផ្ទៃពោះ គឺជាការសំខាន់ដែលអ្នកត្រូវចាក់ថ្នាំបង្ការរោគរបស់អ្នកឱ្យបានទាន់បច្ចុប្បន្នភាព ដោយហេតុថាភាពស៊ាំនឹងជំងឺរបស់អ្នកនឹងត្រូវបន្តទៅឱ្យទារករបស់អ្នក ហើយការនេះនឹងផ្តល់នូវការការពារក្នុងប៉ុន្មានសប្តាហ៍នៃជីវិតរបស់ទារក មុននឹងគេអាចទទួលការចាក់ថ្នាំបង្ការរោគ។ ជំងឺមួយចំនួនអាចធ្វើឱ្យអន្តរាយដល់ការមានផ្ទៃពោះរបស់អ្នក ដូច្នេះគឺជាការប្រសើរបំផុតដែលអ្នកត្រូវការពារមុនពេលអ្នកមានផ្ទៃពោះ។ ការធ្វើតេស្តដ៏សាមញ្ញមួយអាចបង្ហាញថាតើអ្នកបានទទួលការការពារឬអត់។

### រោគកញ្ជ្រឹល ស្រឡទែន និងស្អូច (MMR)

ប្រសិនបើអ្នកឆ្លងរោគកញ្ជ្រឹល ស្រឡទែន និងស្អូចក្នុងអំឡុងពេលមានផ្ទៃពោះ អ្នកអាចរលូតកូន កើតកូនមិនគ្រប់ខែ ឬទារករបស់អ្នកអាចកើតមកមានភាពមិនគ្រប់លក្ខណៈពីកំណើតដ៏ធ្ងន់ធ្ងរ។ ប្រសិនបើអ្នកពុំបានការពារទេ អ្នកគួរតែចាក់ថ្នាំបង្ការរោគ។ ជាការសំខាន់ដែលអ្នក**មិនត្រូវមានផ្ទៃពោះក្នុងរយៈពេល២៨ថ្ងៃ បន្ទាប់ពីបានចាក់ថ្នាំបង្ការរោគ។**



### រោគអុតតូច (អុតស្វាយ)

រោគអុតស្វាយ អាចបណ្តាលឱ្យមានភាពពុំគ្រប់លក្ខណៈពីកំណើតយ៉ាងធ្ងន់ធ្ងរ ប្រសិនបើអ្នកឆ្លងរោគនេះក្នុងអំឡុងពេលមានផ្ទៃពោះ។ អ្នកគួរចាក់ថ្នាំបង្ការរោគ ប្រសិនបើអ្នកមិនបានការពារទេ។ **បន្ទាប់ពីការចាក់ថ្នាំបង្ការរោគ អ្នកត្រូវជៀសវាងកុំឱ្យមានផ្ទៃពោះក្នុងរយៈពេល២៨ថ្ងៃ។**

## ខណៈពេលដែលអ្នកកំពុងមានផ្ទៃពោះ

### រោគរលាកថ្លើមប្រភេទ B

ស្ត្រីមានផ្ទៃពោះគ្រប់រូប ត្រូវបានធ្វើតេស្តរកមើលការឆ្លងរោគរលាកថ្លើមប្រភេទ B ដោយហេតុថាវាអាចចម្លងបន្តទៅទារករបស់ពួកគេ ក្នុងអំឡុងពេលសម្រាលកូន។ ប្រសិនបើអ្នកមានជំងឺ អ្នកប្រហែលជាចាំបាច់ត្រូវទៅជួបគ្រូពេទ្យឯកទេសពិនិត្យអ្នក ហើយទារករបស់អ្នកនឹងចាំបាច់ទទួលការចាក់ថ្នាំពីរម្ជុល ក្នុងរយៈពេល១២ម៉ោងក្រោយពីបានកើតមក។ ដោយគ្មានការព្យាបាលនេះទេ ទារករបស់អ្នកអាចកើតរោគរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃ ដែលអាចនាំឱ្យមានបញ្ហាសុខភាពយ៉ាងធ្ងន់ធ្ងរទាំងឡាយ ដូចជាការខូចថ្លើម ឬជំងឺមហារីកថ្លើម។

### រោគក្អកមាន់

ថ្នាំចាក់បង្ការរោគក្អកមាន់ ជាទូទៅត្រូវបានផ្តល់ឱ្យស្ត្រីមានផ្ទៃពោះនៅ២៨សប្តាហ៍ (អាចផ្តល់ឱ្យបានគ្រប់ពេលចន្លោះពី២០-៣២សប្តាហ៍) នៃការមានផ្ទៃពោះម្តងៗ ហើយគួរតែបានផ្តល់ឱ្យជាឆាប់បំផុត (ចាប់ពី២០សប្តាហ៍) ដល់ស្ត្រីដែលត្រូវបានកំណត់ថាមានហានិភ័យខ្ពស់នៃការកើតកូនមុនពេលកំណត់។ ការនេះនឹងផ្តល់ការការពារសម្រាប់អ្នក និងទារករបស់អ្នក ដោយហេតុថាអង្គបដិបក្ខនឹងបន្តឱ្យទារករបស់អ្នកនៅក្នុងស្បូន។ ការចាក់ថ្នាំបង្ការរោគក្អកមាន់ក្នុងអំឡុងពេលមានផ្ទៃពោះ មានសុវត្ថិភាពទាំងម្តាយ និងទារកដែលមិនទាន់កើត។

អ្នកគួរស្នើសុំឱ្យដៃគូរបស់អ្នក ជីដូនជីតារបស់ទារកអ្នក និងអ្នកមើលថែពេញពេញវ័យជិតស្និទ្ធដទៃទៀត ឱ្យចាក់ថ្នាំបង្ការរោគយ៉ាងហោចណាស់ពីរសប្តាហ៍មុនពេលទារករបស់អ្នកកើតមក ប្រសិនបើពួកគេមិនបានថ្នាំបង្ការរោគក្អកមាន់ក្នុងរយៈពេល១០ឆ្នាំកន្លងមកនេះ។

### គ្រុនផ្តាសាយធំ

គ្រុនផ្តាសាយធំក្នុងពេលមានផ្ទៃពោះ អាចមានភាពធ្ងន់ធ្ងរ ជាមួយនឹងការកើនឡើងនៃហានិភ័យការកើតកូនមិនគ្រប់ខែ និងផលវិបាកផ្សេងៗទៀត។ ការចាក់ថ្នាំបង្ការគ្រុនផ្តាសាយធំក្នុងអំឡុងពេលមានផ្ទៃពោះ មានសុវត្ថិភាព និងមានប្រសិទ្ធភាព ហើយត្រូវបានណែនាំយ៉ាងខ្លាំងសម្រាប់ស្ត្រីមានផ្ទៃពោះទាំងអស់។ ថ្នាំបង្ការគ្រុនផ្តាសាយធំ ផ្តល់ជូនដោយឥតគិតថ្លៃសម្រាប់ស្ត្រីមានផ្ទៃពោះ ហើយក៏ផ្តល់ការការពារដល់ទារករបស់អ្នកក្នុងស្បូន និងក្នុងអំឡុងពេលប៉ុន្មានខែដំបូងនៃជីវិតផងដែរ។

## បន្ទាប់ពីសម្រាលកូន

វាមានសុវត្ថិភាពសម្រាប់អ្នក ដើម្បីទទួលការចាក់ថ្នាំបង្ការរោគជាប្រចាំឱ្យបានភ្លាមៗ ក្រោយពេលទារកកើតមក ទោះបីជាអ្នកកំពុងបំបៅកូនដោយទឹកដោះម្តាយក៏ដោយ។ អ្នកគួរតែបានចាក់ថ្នាំបង្ការរោគក្អកមាន់ មុនពេលអ្នកចេញពីមន្ទីរពេទ្យ ប្រសិនបើអ្នកមិនបានចាក់ថ្នាំបង្ការរោគក្នុងអំឡុងពេលអ្នកមានផ្ទៃពោះ។

ការចាក់ថ្នាំលើកទីមួយរបស់ទារកអ្នក គឺរោគរលាកថ្លើមប្រភេទ B ត្រូវបានណែនាំបន្ទាប់ពីសម្រាលកូនរួចភ្លាម ហើយការចាក់ថ្នាំតាមគម្រោងបន្ទាប់នឹងដល់កំណត់នៅពេលទារករបស់អ្នកមានអាយុ៦អាទិត្យ។

ទារកកើតពីម្តាយដែលមានរោគរលាកថ្លើមប្រភេទ B ចាំបាច់ត្រូវការធ្វើតេស្តឈាម ៣ខែបន្ទាប់ពីបានបំពេញវគ្គចាក់ថ្នាំបង្ការរោគរលាកថ្លើមប្រភេទ B ដើម្បីឱ្យប្រាកដថាពួកគេបានទទួលការការពារ។ អ្នក និងវេជ្ជបណ្ឌិតរបស់អ្នកនឹងបានទទួលលិខិតរំលឹកមួយច្បាប់ពីក្រសួងសុខាភិបាល រដ្ឋញូវសៅវែល។

*ជាការសំខាន់ដែលអ្នកត្រូវចាក់ថ្នាំបង្ការរោគរបស់អ្នក ឱ្យបានទាន់បច្ចុប្បន្នភាព ដោយហេតុថាភាពស៊ាំនឹងជំងឺរបស់អ្នក នឹងត្រូវបន្តទៅឱ្យទារករបស់អ្នក។*